រដ្ឋសភាជាតិក្នុងខែមេសា ដល់ខែមិថុនា ឆ្នាំ២០១១ គឺជារយៈពេលសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៦ដែលស្ថិតនៅក្នុងរយៈពេលនេះ រដ្ឋសភាបានអនុម័តនូវសេចក្តីព្រាងច្បាប់សេចក្តីស្នើច្បាប់និងកិច្ចព្រមព្រៀងផ្សេងៗ។

បើទោះជាក្នុងពេលនេះ រដ្ឋសភាមានការមមាញឹកក្នុងការពិភាក្សាលើសេចក្តីព្រាងច្បាប់ក្តី ក៏អ្នកតំណាងរាស្ត្របានខិតខំចុះមូលដ្ឋានដើម្បីជួបប្រជាពលរដ្ឋអាជ្ញាធរក្នុងគោលបំណងផ្សេងៗ។

## ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងពេលប្រជុំពេញអង្គ

### អ្នកតំណាងរាស្ត្រត្រូវបានហាមឃាត់មិនឲ្យបញ្ចេញមតិក្នុងករណីមិនគាំទ្រសេចក្តីព្រាងច្បាប់

ការជជែកពិភាក្សាក៏ដូចការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រទៅលើសេចក្តីព្រាងច្បាប់មានសារៈសំខាន់ណាស់ដើម្បីធ្វើឲ្យសេចក្តីព្រាងច្បាប់ និងរបៀបវារៈដែលរដ្ឋសភាត្រូវអនុម័តនោះត្រូវបានតំណាងរាស្ត្រអាចស្វែងរកនូវកង្វះខាត និងផលប៉ះពាល់របស់សេចក្តីព្រាងច្បាប់។

ការពិភាក្សានេះក៏ជាវេទិកាអប់រំ និងផ្តល់ចំនេះដឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍ជាតិកម្ពុជា) ដល់ប្រជាពលរដ្ឋពីអត្ថន័យ និងទោសទណ្ឌរបស់ច្បាប់ដែលរដ្ឋសភានឹងអនុម័ត រួមទាំងអាចសង្កេតពីភាពសកម្មក្នុងការបញ្ចេញមតិរបស់តំណាងរបស់ខ្លួន។ តែការសង្កេតក្នុងសម័យប្រជុំលើកទី៦ចន្លោះពីខែមេសា-មិថុនា ការប្រជុំរបស់រដ្ឋសភាលើសេចក្តីព្រាងច្បាប់ដែលស្នើដោយរាជរដ្ឋាភិបាល គឺភាគច្រើនទុកជាការប្រញាប់ដែលតំរូវឲ្យប្រធានអង្គប្រជុំតែងតែពន្លឿនពេលការប្រជុំដោយកាត់បន្ថយ ឬរារាំងការឡើងបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រមួយចំនួនលើសេចក្តីព្រាងច្បាប់ មិនថាសេចក្តីព្រាងច្បាប់ ឬរបៀបវារៈនោះសំខាន់ដែលពាក់ព័ន្ធនឹងសុវត្ថិភាពជាតិ និងច្បាប់ដែលទាមទារឲ្យមានការពិនិត្យពិច្ច័យមុននឹងលើកដៃ។

ក្នុងកំឡុងពេលសង្កេតមានសេចក្តីព្រាងច្បាប់ចំនួន ១៣ ត្រូវបានសភាពិភាក្សានិងអនុម័ត ហើយក្នុងនោះមានសេចក្តីព្រាងច្បាប់ចំនួន១១ ដែលសភាប្រកាសប្រញាប់ ហើយសេចក្តីព្រាងច្បាប់ខ្លះអ្នកតំណាងរាស្ត្រមិនអាចបញ្ចេញមតិឲ្យបានគ្រប់ជ្រុងជ្រោយ ឬត្រូវប្រធានហាមឃាត់។

ជាក់ស្តែងក្នុងការពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពីការអនុម័ត និងយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនខេមបូខាអ៊ិនធើរណេស្សូណលអ៊ិនវេស្តមែនឌីវើឡុបមែនគ្រុប ដែលជាច្បាប់តម្រូវឲ្យរាជរដ្ឋាភិបាលយកលុយរដ្ឋសងដល់ក្រុមហ៊ុនក្នុងពេលក្រុមហ៊ុនរកស៊ីខាតគឺ ប្រធានរដ្ឋសភាបានបិទមិនឲ្យអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងបញ្ចេញមតិឡើយ។

ការហាមឃាត់បានកើតឡើងនៅពេលអ្នកតំណាងរាស្ត្រ **មូរ សុខហួរ** មកពីគណបក្សសមរង្ស៊ីសុំឡើងបញ្ចេញមតិដោយប្រធានអង្គប្រជុំលើកហេតុផលថា អ្នកតំណាងរាស្ត្រគណបក្សនេះមិនបានលើកដៃអនុម័តគាំទ្រលើសេចក្តីព្រាងច្បាប់នេះនៅជំពូកមុន។ សម្តេចប្រធានរដ្ឋសភាបានអះអាងថា "*ការពិភាក្សាមានតែគណបក្សប្រឆាំងទេដែលសុំមានមតិយោបល់*"។ ប៉ុន្តែនៅពេលតំណាងរាស្ត្រគណបក្សប្រឆាំងស្នើបញ្ចេញមតិ សម្តេចប្រធានបែលើកហេតុផលថា"*មតិឯកឧត្តមវាគ្មិនខាងប្រឆាំងច្រើនតែមិនចំតាមប្រធានបទនៃការពិភាក្សា។ លោកជំទាវ មូរ សុខហួរ បានប្រកាសហើយថា តំណាងអោយគណបក្សជំទាស់ថា មិនគាំទ្រ មិនអនុម័ត។ អញ្ចឹងអាស្រ័យប្រធានអង្គប្រជុំ ឬប្រធានសភាឲ្យបញ្ចេញមតិ ឬមិនឲ្យអញ្ចឹង សូមអនុម័ត*

*តែម្តង*។ ការមិនអនុញ្ញាតឲ្យមានការពិភាក្សានេះហើយបានបង្កើតទំនាស់ និងការប្រឆាំងតបវិញ ដោយអ្នកតំណាងរាស្ត្រ មូរ សុខហួរ រួមទាំងអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីផ្សេងទៀតបានដើរចេញពីសាលប្រជុំ។

នៅក្នុងការពិភាក្សា និងអនុម័តបទបញ្ជាផ្ទៃក្នុងសមាជជាតិ អ្នកតំណាងរាស្ត្រ មូរ សុខហួរ ក៏ត្រូវប្រធានអង្គប្រជុំដែលជាអនុប្រធានទី១ព្រឹទ្ធសភាព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវ័នមុនីរក្ស ក្នុងសមាជរដ្ឋសភា និងព្រឹទ្ធសភាមិនអនុញ្ញាតឲ្យបញ្ចេញមតិឲ្យអស់រយៈពេលដែលខ្លួនត្រូវមានដែរ។ ដោយប្រធានអង្គប្រជុំលើកហេតុផលថា ខ្លឹមសារនៃជំពូកទី៦ដែលអ្នកតំណាងរាស្ត្រនេះចង់បញ្ចេញមតិស្រដៀង ឬមានទំនាក់ទំនងនឹងជំពូកទី៥ និងម្យ៉ាងទៀតសមាជមានជំពូកផ្សេងទៀតត្រូវពិភាក្សាបញ្ចប់។

ជាលទ្ធផលអ្នកតំណាងរាស្ត្រ មូរ សុខហួរ ត្រូវអនុញ្ញាតពេលតែ២នាទីប៉ុណ្ណោះខណៈជាក់ស្តែងគឺត្រូវមានពេល១០នាទី។ ប្រធានអង្គប្រជុំបានបញ្ជាក់ថា *"...ឥឡូវចូលមកដល់ជំពូកទី៦ដូចលោកជំទាវមានប្រសាសន៍ហើយថា ទី៦ និងទី៥ដូចគ្នាខ្ញុំសូមជូន២នាទីទៀតដើម្បីបញ្ចប់...ក្នុងជំពូកទី៦ នេះខ្ញុំអាចជូនពេល២នាទី ខ្ញុំមិនអាចជូនលើសពីនេះទេដោយការប្រជុំសមាជមាន ៤ជំពូកទៀត សូមអញ្ជើញតើយកតែ២នាទី ឬមិនយក"*។

ជាការឆ្លើយតបអ្នកតំណាងរាស្ត្របានព្យាយាមតវ៉ា *"ក្រែងខ្ញុំម្ចាស់មិនយល់ ភ្លេចអ្វីដែលជាបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៅពេលនេះយើងយកបទបញ្ជាផ្ទៃក្នុងរដ្ឋសភាមកនិយាយ ពីព្រោះយើងមិនទាន់អនុម័តសមាជទេព្រះអង្គ ដូច្នេះក្នុងក្រុមយើងខ្ញុំក្នុងជំពូកទី៦មាន១០នាទីត្រូវតែជជែក"*។

បើតាមការអង្កេតរបស់អ្នកអង្កេតការណ៍ខុមហ្វ្រែលនៅសាលប្រជុំ ការជជែកតវ៉ារវាងអ្នកតំណាងរាស្ត្រមូរសុខហួរ និងប្រធានអង្គប្រជុំបានចំណាយពេលជាង៨នាទីគ្រាន់តែជជែកតវ៉ាគ្នា។

ជាគោលការណ៍ប្រជាធិបតេយ្យ ប្រធានអង្គប្រជុំមិនគួរណាប្រើប្រាស់ហេតុផលពន្លឿនកិច្ចប្រជុំ ឬគ្មានពេលគ្រប់គ្រាន់មកធ្វើជាលេសបិទសិទ្ធិសេរីភាពរបស់អ្នកតំណាងរាស្ត្រក្នុងការបញ្ចេញមតិក្នុងសម័យប្រជុំ ដែលដំណើរការស្របតាមនិតិវិធីនោះទេ។ រដ្ឋធម្មនុញ្ញបានទុកពេល៣ខែសម្រាប់សម័យប្រជុំនីមួយៗ ឬអាចថា ប្រមាណ ៦៥ថ្ងៃធ្វើការ ក៏ប៉ុន្តែការសង្កេតកន្លងមកឃើញថា ការប្រជុំជាក់ស្តែងក្នុងមួយសម័យប្រជុំមានតែប្រមាណ៨ព្រឹកប៉ុណ្ណោះ។ ចំណែកការប្រជុំលើកទី៦នេះ គឺមាន៨ព្រឹក និង១ល្ងាចប៉ុណ្ណោះ។

អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ លោក ស៊ូប៊ែឌី ក្នុងបេសកកម្មរបស់គាត់រយៈពេល៥ថ្ងៃ នៅចុងខែឧសភា ឆ្នាំ២០១១ ខណៈដែលមានឱកាសសំដែងការគួរសមជាមួយនឹងរដ្ឋសភាកម្ពុជាក្នុងរយៈពេលថ្មីៗនេះ ធ្លាប់បានមានប្រសាសន៍ថារដ្ឋសភាសព្វថ្ងៃក្នុងការជជែកពិភាក្សាលើសេចក្តីព្រាងច្បាប់ គឺមិនសូវបើកទូលាយឲ្យតំណាងរាស្ត្របានជជែកស៊ីជំរៅលើសេចក្តីព្រាងច្បាប់ទេ និងរួមទាំងការបញ្ចេញមតិការពារប្រយោជន៍ជាតិក៏ត្រូវប្រឈមនឹងការចាត់ប្រកាន់ *"វិសាលភាពសម្រាប់សមាជិកសភា ក្នុងការចូលរួមជជែកដេញដោលត្រូវបានកម្រិត ...សូម្បីតែការបញ្ចេញមតិអំពីបញ្ហានានា ដែលជាផលប្រយោជន៍ជាតិក្តី"*។

# របាយការណ៍លើការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ

**រូបសញ្ញាគណបក្សប្រើក្នុងរបាយការណ៍នេះ៖**

គណបក្ស ប្រជាជនកម្ពុជា

គណបក្ស សមរង្ស៊ី

គណបក្ស សិទ្ធិមនុស្ស

គណបក្ស ហ៊្វុនស៊ិនប៉ិច

គណបក្ស នរោត្តមរណឫទ្ធិ

រដ្ឋសភាក្នុងរយៈពេល៣ខែនេះ បានបើកសម័យប្រជុំលើកទី៦របស់ខ្លួន ចំនួន**៨ព្រឹក** និង**១ល្ងាច**បានពិភាក្សា និងអនុម័តលើរបៀបវារៈចំនួន**១៦** ដែលក្នុងនោះមាន ៨ជាច្បាប់សេចក្តីព្រាង ២ជាវិសោធនកម្ម ៣ជាការផ្តល់សច្ចាប័ន និងកិច្ចព្រមព្រៀងនិងផ្សេងៗទៀតចំនួន៣ ដូចជាការលើកដៃអនុម័តលើការសុំឈប់សំរាកព្យាបាលជំងឺរបស់អ្នកតំណាងរាស្ត្រ អ៊ុន នឹង មានន័យថាជាមធ្យមរដ្ឋសភាពិភាក្សា និងអនុម័តក្នុង១ព្រឹកបានប្រមាណ២របៀបវារៈ។

ក្នុងកំឡុងពេលនេះ មានតែអ្នកតំណាងរាស្ត្រចំនួន **១៩រូប** មកពីគណបក្សចំនួន៣ ក្នុងចំណោមគណបក្សចំនួន៥ មានអាសនៈនៅរដ្ឋសភាបានឡើងបញ្ចេញមតិមានចំនួន **៨៤៩នាទី** ជាពិសេសទៅលើតួអង្គរាជរដ្ឋាភិបាល ការផ្តល់អនុសាសន៍លើសេចក្តីព្រាងច្បាប់កំពុងពិភាក្សារបៀបវារៈកំពុងពិភាក្សា តួអង្គរដ្ឋសភា និងតួអង្គជាតំណាងរាស្ត្រដ៏ទៃ។

ជាមធ្យមអ្នកតំណាងរាស្ត្រ១រូបបញ្ចេញមតិបាន៤៥នាទី ព្រោះថាភាគច្រើនប្រធានក្រុមនៃអ្នកតំណាងរាស្ត្របានឡើងបញ្ចេញមតិពិភាក្សាច្រើនជាងគេ។

ចំណែកខ្លឹមសារនៃការបញ្ចេញមតិទៅលើតួអង្គខាងលើក្នុងន័យអព្យាក្រឹតមានចំនួន៤៣០នាទី (ស្មើនឹង៥១%នៃការបញ្ចេញមតិសរុប) ខ្លឹមសារវិជ្ជមាន ឬសរសើរដល់តួអង្គខាងលើមានចំនួន១១២នាទី (១៣%) និងខ្លឹមសារអវិជ្ជមាន ឬរិះគន់មានចំនួន៣០៧ (ស្មើនឹង៣៦%)។

អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា បានគាំទ្ររាល់គ្រប់សេចក្តីព្រាង/ស្នើច្បាប់ដែលរាជរដ្ឋាភិបាលស្នើនោះ បានឡើងបញ្ចេញមតិចំនួន៩រូប (ស្ត្រី១រូប) ចំនួន២៩ដង ស្មើនឹង២៤៣នាទី ដែលជាមធ្យមអ្នកតំណាងរាស្ត្រគណបក្សនេះ១រូបបញ្ចេញមតិបាន២៧នាទី។ ការបញ្ចេញមតិភាគច្រើនរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សនេះ គឺលើកសរសើរលើការងាររបស់រាជរដ្ឋាភិបាលដែលបានខិតខំប្រឹងប្រែងដើម្បីធ្វើច្បាប់ នាយករដ្ឋមន្ត្រី រដ្ឋសភា គណបក្សរបស់ខ្លួន និងការឆ្លើយតបនឹងតំណាងរាស្ត្រដ៏ទៃក្នុងន័យបំភ្លឺ និងលើកអំណះអំណាងជួយការពារសេចក្តីព្រាងច្បាប់ ក៏ដូចជាឆ្លើយឆ្លងជាមួយនឹងអ្នកតំណាងរាស្ត្រដ៏ទៃមកពីគណបក្សផ្សេងផងដែរ។

ចំណែកអ្នកតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ីបានឡើងបញ្ចេញមតិចំនួន៩រូប (ស្ត្រី២រូប) បានឡើងបញ្ចេញមតិចំនួន៤១ដង ដែលស្មើនឹង៥៨១នាទី។ ជាមធ្យមតំណាងរាស្ត្រ១រូបបញ្ចេញមតិបាន៦៥នាទី។ ការបញ្ចេញមតិភាគច្រើន គឺផ្តោតលើការលើកឡើងក៏ដូចជាផ្តល់អនុសាសន៍ និងលើកជាសំណួរដល់រាជរដ្ឋាភិបាលជាអ្នកការពារសេចក្តីព្រាងច្បាប់ កខ្វះខាតរបស់សេចក្តីព្រាងច្បាប់ តុលាការ នាយករដ្ឋមន្ត្រី តួអង្គរាជរដ្ឋាភិបាល គណបក្សរបស់ខ្លួន និងបញ្ហាប្រឈមផ្សេងៗរបស់មណ្ឌល។

អ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ១រូប បានបញ្ចេញមតិចំនួន២៥នាទី ដែលការបញ្ចេញមតិនេះនិយាយពាក់ព័ន្ធនឹងរដ្ឋសភា អនុសាសន៍លើសេចក្តីព្រាងច្បាប់ របៀបវារៈកំពុងពិភាក្សា និងរាជរដ្ឋាភិបាល។

ចំណែកអ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបន្តឈឺចាប់ដោយគ្មានសម្លេង និងមតិក្នុងរដ្ឋសភា ហើយក៏មិនបានលើកដៃគាំទ្រលើសេចក្តីព្រាងច្បាប់មួយចំនួនដែរ។

**ក្រាហ្វិចទី១៖ ភាគរយអ្នកតំណាងរាស្ត្របានបញ្ចេញមតិក្នុងពេលប្រជុំពេញអង្គរដ្ឋសភាលើកទី៦ (មេសា-មិថុនា) ធៀបនឹងចំនួនសរុបតាមគណបក្សបក្ស**




អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចំនួន៩រូបបានបញ្ចេញមតិក្នុងសម័យប្រជុំលើកទី៦នេះស្មើនឹង១០% នៃចំនួនអ្នកតំណាងរាស្ត្រសរុប របស់គណបក្សនេះ ៩០រូប ដែលចំនួននេះតិចជាងសម័យប្រជុំលើកទី៥ (ខែតុលា-ធ្នូ) មានអ្នកតំណាងរាស្ត្រ១២ រូបចូលរួមបញ្ចេញមតិយោបល់ លើសេចក្តីព្រាងច្បាប់។

អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីចំនួន៩រូបដែរបានឡើងបញ្ចេញមតិស្មើនឹង៣៥% នៃចំនួនតំណាងរាស្ត្រសរុប ២៦អាសនៈគឺកើនជាងរយៈពេលប្រជុំរដ្ឋសភាលើកទី៥ដែលមានតែ៦រូប។ ដោយឡែកក្នុងសម័យប្រជុំលើកនេះក៏មានវត្តមានអ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ១រូប ក្នុងចំណោម២រូបបានឡើងបញ្ចេញមតិ។

**តារាងទី១៖អ្នកតំណាងរាស្ត្របានបញ្ចេញមតិច្រើនជាងគេ៥រូប ក្នុងសម័យប្រជុំលើកទី៦**

| លរ | ឈ្មោះអ្នកតំណាងរាស្ត្រ | គណបក្ស | ចំនួនដង | អញ្ញត្រឹត | វិជ្ជមាន | អវិជ្ជមាន | សរុប |
|---|---|---|---|---|---|---|---|
| ១ | ឯកឧត្តម សុន ឆ័យ | | ១៥ | ១៣៧ | ១២ | ៦៦ | ២១៥ |
| ២ | ឯកឧត្តម យឹម សុវណ្ណ | | ៩ | ៥៤ | ១៤ | ៦៥ | ១៣៣ |
| ៣ | ឯកឧត្តម ជាម យៀប | | ៩ | ៦៣ | ១៣ | ៦ | ៨២ |
| ៤ | លោកជំទាវ មូរ សុខហួរ | | ៦ | ៣២ | ១១ | ២៨ | ៧១ |
| ៥ | ឯកឧត្តម ហូរ វ៉ាន់ | | ៤ | ៣៣ | ៣ | ២៣ | ៥៩ |

អ្នកតំណាងរាស្ត្រ សុន ឆ័យ មកពីគណបក្សសមរង្ស៊ីមណ្ឌលភ្នំពេញជាអ្នកតំណាងរាស្ត្របានបញ្ចេញមតិច្រើនជាងគេមានដល់ទៅ១៥លើក ស្មើនឹង២១៥នាទី ឬ៣ម៉ោង៣៥នាទី ដែលភាគច្រើនក្នុងការបញ្ចេញមតិនេះ គឺក្នុងន័យអញ្ញត្រឹត ហើយបើទោះជាការបញ្ចេញមតិក្នុងន័យអវិជ្ជមានមានតែ៦៦នាទី តែជាចំនួនច្រើនជាងគេបើធៀបនឹងអ្នកតំណាងរាស្ត្រដ៏ទៃបានបញ្ចេញមតិ។

អ្នកតំណាងរាស្ត្រ យឹម សុវណ្ណ មណ្ឌលភ្នំពេញគណបក្សសមរង្ស៊ីឈរលេខរៀងទី២បានបញ្ចេញមតិចំនួន៩លើកស្មើនឹង១៣៣នាទី(ឬ២ម៉ោង១៣នាទី) បានបញ្ចេញមតិក្នុងន័យវិជ្ជមានច្រើនជាងគេចំនួន១៤នាទី។

អ្នកតំណាងរាស្ត្រលេខរៀងទី៣ គឺអ្នកតំណាងរាស្ត្រ ជាម យៀប មកពីគណបក្សប្រជាជនកម្ពុជាមណ្ឌលព្រៃវែងបានបញ្ចេញមតិចំនួន៩លើកដែរ គឺ៨២នាទី។

## សេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ និងសំលេងអនុម័តដែលរដ្ឋសភាបានអនុម័តនិងពិភាក្សាក្នុងសម័យប្រជុំលើកទី៦

| ល.រ | ថ្ងៃ ខែ អនុម័ត | សេចក្តីព្រាងច្បាប់និងសេចក្តីស្នើច្បាប់ | សំលេង អនុម័ត |
|---|---|---|---|
| ១ | ០១ មេសា | -ការពិភាក្សា និងអនុមត័សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ | ៨៥/៩៥ |
| ២ | ០៦ មេសា | -ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី | ៨៣/៩៧ |
| ៣ | ០៧ មេសា | -ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៨ | ៦៦/៨២ |
| ៤ | ០៧ មេសា | -ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៩ | ៦៨/៨៤ |
| ៥ | ០៧ មេសា | -ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអោយក្រុមហ៊ុនអគ្គិសនីវៀតណាម | ៧១/៨៤ |
| ៦ | ០៧ មេសា | -ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី២ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន | ៧៧/៨៤ |
| ៧ | ២៦ មេសា | -ការពិភាក្សា និងអនុម័តសេចក្តីស្នើរច្បាប់ស្តីពីបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា | ១៣១/១៥៥ |
| ៨ | ១១ ឧសភា | -ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ៨៦/៩៩ |
| ៩ | ១១ ឧសភា | -ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ | ៧៩/៩៩ |
| ១០ | ១១ ឧសភា | -ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតំណាងរាស្ត្រ | ៧៩/៩៩ |
| ១១ | ១៦ មិថុនា | -ការពិភាក្សា និងអនុមត័សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញារវាងព្រះរាជាណាចក្រកម្ពុជាសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីការកំណត់ចំណុចប្រសព្វនៃខ្សែព្រំដែនប្រទេសទាំង៣ | ៨៣/១០០ |
| ១២ | ១៦ មិថុនា | -ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៣ធ្វើវិសោធនកម្មលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ | ៩៤/១០១ |
| ១៣ | ១៦ មិថុនា | -ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនខេមបូឌាអ៊ិនធើរណេស្យូណលអ៊ិនវេស្តមែន ឌីវើឡុបមែនគ្រុប | ៨៣/១០០ |

## ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

តាមទិន្នន័យខុមហ្វ្រែលដែលទទួលបានបង្ហាញថា ក្នុងរយៈពេល៣ខែនេះ(មេសា ដល់មិថុនា២០១១) អ្នកតំណាងរាស្ត្របានចុះមូលដ្ឋានច្រើនជិតប្រហាក់ប្រហែលនឹងត្រីមាសមុន (តុលា-ធ្នូ២០១០ជាពេលចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ)។

ក្នុងរយៈពេលនេះ មានអ្នកតំណាងរាស្ត្រយ៉ាងតិច៧៤រូប (ឬ៦០% នៃអ្នកតំណាងរាស្ត្រសរុប១២៣រូប) បានចុះមូលដ្ឋានសរុបបានយ៉ាងតិច៥៥៩លើក គឺតិចជាងរយៈពេល៣ខែមុនប្រមាណ១២% (ពីខែតុលា ដល់ធ្នូ ២០១០ អ្នកតំណាងរាស្ត្រចុះមូលដ្ឋានបានសរុប៦៣៨លើក)។

ទោះបីយ៉ាងណា ខុមហ្វ្រែលមិនបានទទួលព័ត៌មានពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៅក្នុងមណ្ឌលចំនួន៥ គឺមណ្ឌលកែប មណ្ឌលស្ទឹងត្រែង មណ្ឌលមណ្ឌលគីរី មណ្ឌលកំពង់ចាម និងបាត់ដំបងនោះទេ។

***<u>ក្រាហ្វិទី២៖ ភាគរយកំណើននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សចន្លោះពីខែមេសា-មិថុនា ២០១១ ធៀបនឹងមករា-មីនា ២០១១</u>***




បើគិតជាចំនួនចុះមូលដ្ឋានសរុបតាមគណបក្ស តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និងអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី បានចុះមូលដ្ឋានច្រើនជាងគេ ដោយសារគណបក្សទាំងពីរនេះមានអ្នកតំណាងរាស្ត្រច្រើន។

ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមានការកើនឡើងច្រើនជាងគេក្នុងត្រីមាសនេះ គឺ១០៤% មានចំនួន១៩២លើក ដែលត្រីមាសមុន គឺមានត្រឹមតែ៩៤លើក។

ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សទាំង៣រូបក៏បានបង្កើនការចុះមូលដ្ឋានរបស់ខ្លួនរហូតដល់១០៩លើក គឺកើនឡើងប្រមាណ៧៣%ធៀបនឹង៣ខែមុន (ពីមករា ដល់មីនា ឆ្នាំ២០១១ អ្នកតំណាងរាស្ត្រមកពីគណបក្សសិទ្ធិមនុស្ស បានចុះមូលដ្ឋានចំនួន៦៣ លើក)។

អ្នកតំណាងរាស្ត្រគណបក្ស នរោត្តមរណឫទ្ធិក៏បានចុះមូលដ្ឋានកើនឡើង២ដង ដែរ សរុប៦ (ត្រីមាសមុនចុះបាន៣លើក) និងហ្វ៊ុនស៊ិនប៉ិចកើនដល់១៥លើក កើនចំនួន១៥% (៣ខែមុនមានចំនួន១៣លើក )។

ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានថយចុះដល់៤៩% ដែលមានចំនួន២៣៧លើកក្នុងត្រីមាសនេះ គឺតិចជាងត្រីមាសមុនដែលអ្នកតំណាងរាស្ត្រគណបក្សនេះចុះមូលដ្ឋានបាន ៤៦៥លើក និងចំនួនតំណាងរាស្ត្របានថយពី៦៥រូបដល់៥៣រូបផងដែរ។

ក្នុងចំណោមតំណាងរាស្ត្រទាំង៧៤រូបដែលបានចុះមូលដ្ឋាន មានតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាសរុប៥៣រូប (ស្មើនឹង៥៩%នៃតំណាងរាស្ត្រគណបក្សនេះសរុប៩០រូប)។ តំណាងរាស្ត្រគណបក្សសមរង្ស៊ីសរុប១៤រូប (ស្មើនឹង៥៤%នៃតំណាងរាស្ត្រគណបក្សនេះសរុប២៦រូប)។ ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចំនួន៣រូប តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចទាំង២រូប និងតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ២រូប បានចុះមូលដ្ឋានទាំងអស់ ។

ទោះបីយ៉ាងណាបើគិតជាមធ្យមនៃតំណាងរាស្ត្រម្នាក់ៗ ដែលចុះមូលដ្ឋានតាមគណបក្សវិញឃើញថាតំណាងរាស្ត្រ

គណបក្សសិទ្ធិមនុស្សជាមធ្យមចុះបានច្រើនជាងគេ ដោយក្នុងតំណាងរាស្ត្រមួយរូបចុះមូលដ្ឋានជាមធ្យមបាន៣៦លើក តំណាងរាស្ត្រគណបក្សសមរង្ស៊ីជាមធ្យមម្នាក់បាន៩លើក តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាជាមធ្យមបាន៥លើក គណបក្សហ៊្វុនស៊ិនប៉ិច៨លើកក្នុង១រូប និងគណបក្សនរោត្តមរណឫទ្ធិ៣លើកក្នុង១រូប។

***ក្រាហ្វិកទី២៖ ភាគរយចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបភាគរយនៃអាសនៈសភាសរុបតាមគណបក្ស***




បើគិតតាមសមាមាត្រភាគរយនៃតំណាងរាស្ត្រក្នុងរដ្ឋសភាតាមគណបក្ស និងភាគរយនៃការចុះមូលដ្ឋានសរុប តាមគណបក្ស បង្ហាញថា ចំនួនចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ដែលមានអាសនៈប្រមាណ៣%បានចុះមូលដ្ឋានបានប្រមាណ២០% ស្មើនឹងជិត៧ដងនៃចំនួនអាសនៈសរុបរបស់គណបក្សនេះ។

ចំណែកអ្នកតំណាងរាស្ត្រ គណបក្សសមរង្ស៊ីដែលមានអាសនៈ២១% នៅក្នុងរដ្ឋសភាបានចុះមូលដ្ឋានប្រមាណ៣៤%។

ចំណែកអ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ និងហ៊្វុនស៊ិនប៉ិច គឺស្មើរតែសមាមាត្រទៅនឹងអាសនៈរដ្ឋសភា ដែលគណបក្សនីមួយៗទទួលបានក្នុងរដ្ឋសភាដែលរួមគ្នាមានអាសនៈ៣%ក្នុងរដ្ឋសភាក៏ចុះមូលដ្ឋានបាន៤%ដែរ។

គណបក្សប្រជាជនកម្ពុជាដែលមានអាសនៈសរុប៧៣%នៅរដ្ឋសភាចុះមូលដ្ឋានបានតែ៤២% នៃការចុះមូលដ្ឋានសរុបដែលចំនួននេះ គឺស្មើនឹងជាងពាក់កណ្តាលនៃចំនួនអាសនៈរបស់គណបក្សនេះក្នុងរដ្ឋសភាប៉ុណ្ណោះ។

***តារាងទី២៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្ស***

| **គោលបំណងនៃការចុះមូលដ្ឋានទាំង៥៥៩លើករបស់តំណាងរាស្ត្រទាំង៧៤រូប** | **គណបក្សនយោបាយ** | | | | | សរុបគោលបំណង |
|---|---|---|---|---|---|---|
| | **៥៣រូប** | **១៤ រូប** | **៣ រូប** | **២ រូប** | **២ រូប** | |
| សាកសួរសុខទុក្ខចែកអំណោយនិងការសម្ពោធសមិទ្ធផលនានា | ១២៨ (៥៤%) | ៥៩ (៣០%) | ៨៧(៨០%) | ២ (១៣%) | ១(១៧%) | ២៧៧ (៥០%) |
| ការចុះពង្រឹងផ្ទៃក្នុងនិងបណ្តាញគណបក្ស | ៤៦ (១៩%) | ១១៩(៦២%) | ១៩(១៧%) | ៧ (៤៧%) | ០ | ១៩១(៣៤%) |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ៥៨ (២៥%) | ០ | ០ | ៤(២៧%) | ៤ (៦៦%) | ៦៦(១១%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ៣(១%) | ៧(៤%) | ៣ (៣%) | ២ (១៣%) | ១(១៧%) | ១៦(៣%) |
| ការអន្តរាគមន៍និងដោះស្រាយបញ្ហានានា | ២(១%) | ៧(៤%) | ០ | ០ | ០ | ៩(២%) |

| | | | | | | |
|---|---|---|---|---|---|---|
| **សរុបគោលបំណងតាមគណបក្ស** | **២៣៧** | **១៩២** | **១០៩** | **១៥** | **៦** | **៥៥៩** |

តារាងទី១បានបង្ហាញថា ការចុះមូលដ្ឋានភាគច្រើនរបស់អ្នកតំណាងរាស្ត្រ គឺផ្តោតទៅលើគោលបំណងសាកសួរសុខទុក្ខចែកអំណោយ និងការសម្ពោធសមិទ្ធផលនានាដែលសរុបមានរហូតដល់២៧៧លើក (ឬ៥០%នៃការចុះមូលដ្ឋានសរុប)។ ការចុះអមដំណើរថ្នាក់ដឹកនាំ១១%។ ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សមាន៣៤%ដែលមានការកើនឡើងជាងរយៈពេល៣ខែមុនព្រោះតែជាពេលកៀកនឹងការបោះឆ្នោតឃុំសង្កាត់២០១២ ខាងមុខនេះដែលគណបក្សកំពុងរៀបចំយុទ្ធសំរាប់ពង្រឹងបក្សរបស់គាត់។ ដោយឡែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុងគោលបំណងចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈមានតិចតួចប៉ុណ្ណោះសរុបបាន១៦លើក (៣%នៃការចុះមូលដ្ឋានសរុប)។ ចំណែកការចុះអន្តរាគមន៍វិញនៅតែមានតិចតួចនៅឡើយ គឺត្រឹម៨លើកស្មើនឹង២%នៃការចុះមូលដ្ឋានសរុប។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា (៥៣រូប ចុះបានសរុប២៣៧លើក)៖** ជាសរុបតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះមូលដ្ឋានច្រើនជាងគណបក្សផ្សេងៗ។ ក្នុងនោះ៧៩% នៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា គឺក្នុងគោលបំណងសួរសុខទុក្ខចែកអំណោយ និងសម្ពោធសមិទ្ធផលនានា(៥៤%) និងក្នុងគោល បំណងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួន (២៥%)។

អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ក៏បានចុះមូលដ្ឋានក្នុងគោលបំណងពង្រឹងគណបក្សរបស់ខ្លួនដែលសរុបមាន១៩%។ ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងចូលរួមវេទិកា និងសិក្ខាសាលាសាធារណៈមាន១% (៣លើក) និងការអន្តរាគមន៍មានចំនួន១% (២លើក)។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានដូចជា៖**

ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ សម្តេចតេជោ ហ៊ុន សែន ជាតំណាងរាស្ត្រមណ្ឌលកណ្តាលបានអញ្ជើញចុះសំណេះសំណាលជាមួយប្រជាពលរដ្ឋ ២០៣គ្រួសារ ស្មើនឹង៩៦២នាក់នៅភូមិគោកត្របែកឃុំស្រឡៅស្រុកបារាយណ៍ខេត្តកំពង់ធំ។ សម្តេច ហ៊ុន សែន ក៏បានដោះស្រាយមួយចំនួនដូចជាការផ្តល់ជូនប្រជាពលរដ្ឋដែលប្រជាពលរដ្ឋរស់នៅក្នុងឃុំនេះមានទំហំដី ៩០៩៧ហិកតាហើយបូកនឹង១០%ជូនប្រជាពលរដ្ឋហើយដោះស្រាយពីបញ្ហាអាងទឹកតំបន់បីដោយត្រូវរំលាយចោលទាំងអស់ ដោយលើកឡើងថា "អ្នកធ្វើអាងនេះមិនមែនប្រជាកសិករធ្វើទេដែលប្រជាពលរដ្ឋមានម៉ាស៊ីនកាយទេមិនមែនទេគឺថៅកែទេអ្នកមានអំណាចទេអ្នកដែលទទួលផលពិតប្រាកដមិនមែនប្រជាកសិករទេ ដោយរក្សាចាស់បំផ្លាញចោលថ្មីអាងទឹកតំបន់បីត្រូវរំលាយទាំងស្រុងដោយលើកលែងបួនឃុំដែលបានប្រកាសរួចហើយដោយអាងអ្នកមាននៅខាងក្រោយ យើងត្រូវតែដោះស្រាយហើយបណ្តាអាងទឹកដែលនៅតំបន់ពីរក្សាអាងទឹកតែត្រូវកែសំរួលបច្ចេកទេស។ ប្រជាជនមានចិត្តសប្បាយរីករាយ នៅពេលសម្តេចបានចាត់វិធានការណ៍បែបនេះ។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសមរង្ស៊ី (១៤រូប ចុះសរុបបាន១៩២លើក)៖** ចំណែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ីបានសួរសុខទុក្ខ(៣០% ឬ៥៩លើកនៃការចុះមូលដ្ឋានរបស់គណបក្សនេះសរុប) ប៉ុន្តែផ្តោតខ្លាំងលើការពង្រឹងបណ្តាញគណបក្ស (ស្មើនឹង៦២% ឬ១១៩លើក) និងការចូលរួមវេទិកាសាធារណៈ និងការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍ស្មើគ្នាដែលសរុបរួមមាន៨%(១៤លើក)។ ចំណែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំខាងគណៈកម្មាធិការខុមហ្វ្រែលមិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋាននេះទេ។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមានដូចជា៖**

អ្នកតំណាងរាស្ត្រ ចាន់ ចេង មណ្ឌលកណ្ដាលបានចុះទៅភូមិព្រែកត្រែង ឃុំសំរោងធំ ស្រុកកៀនស្វាយខេត្តកណ្ដាល ដើម្បីជួយធ្វើអន្តរាគមន៍ករណីទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋចំនួន១០៤ គ្រួសារជាមួយឯកឧត្តមប្រាក់សាវុធជាប្រធានក្រុមប្រឹក្សាខេត្តក្រចេះនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១។ លទ្ធផលគឺមិនជោគជ័យនៅឡើយទេ។ រឿងនេះកំពុងឈានទៅរកការដោះស្រាយព្រោះប្រជាជនមិនព្រមទទួលយកនូវតំលៃដែលឯកឧត្តម ប្រាក់ សាវុធ ផ្ដល់ឲ្យ។ ហើយអ្នកតំណាងរាស្ត្រក៏មិនអាចជួបប្រជាជនត្រូវជាប់ពន្ធនាគារដោយសាររឿងដីធ្លីនេះនៅឡើយដែរ។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស(៣រូប ចុះបានសរុប១០៩លើក)៖**តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបានផ្ដោតលើចុះសួរសុខទុក្ខ ចែកអំណោយដែលមានដល់ទៅ៨៧%(៨០លើក) នៃការចុះមូលដ្ឋានសរុបរបស់គណបក្សនេះ។ ការចុះពង្រឹងគណបក្សមាន១៧% (១៩លើក) និងចូលរួមជាវាគ្មិននៅវេទិកាសាធារណៈ៣% (៣លើក)។

គណៈកម្មាធិការខុមហ្វ្រែល មិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សក្នុងគោលបំណងជួយអន្តរាគមន៍បញ្ហារបស់ប្រជាពលរដ្ឋ និងក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួននោះទេ។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សមានដូចជា៖**

អ្នកតំណាងរាស្ត្រ កឹម សុខា បានចុះមកជួបប្រជុំក្រុមការងារសកម្មជន និងប្រជាពលរដ្ឋនៅឃុំកំពង់ហៅស្រុកកំពង់លែង ឃុំចោងម៉ោង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១១។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច (២រូប ចុះបានសរុប ១៥លើក)៖** អ្នកតំណាងរាស្ត្រគណបក្សនេះទាំងពីររូបសុទ្ធតែបានចុះមូលដ្ឋានសរុប ១៥លើក ដោយផ្ដោតលើការចុះសួរសុខទុក្ខ និងចែកអំណោយមាន២(១៣%) ការពង្រឹង បក្សមាន៧លើកស្មើនឹង៤៧% ចុះអមដំណើរថ្នាក់ដឹកនាំ៤លើក(ស្មើនឹង២៧%នៃការចុះមូលដ្ឋានសរុប) និងការចូលរួមវេទិកា មាន២៧% (៤លើក)។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្ស ហ៊្វុនស៊ិនប៉ិចមានដូចជា៖**

មានអ្នកតំណាងរាស្ត្រ ញឹក ប៊ុនឆៃ មណ្ឌលបន្ទាយមានជ័យបានចុះមកប្រជុំសំណេះសំណាលជាមួយថ្នាក់ដឹកនាំគណបក្សសកម្មជននិងអ្នកគាំទ្រនៅទីស្នាក់ការគណបក្សខេត្តកាលពីថ្ងៃទី០២ខែមិថុនាឆ្នាំ២០១១។

គណៈកម្មាធិការខុមហ្វ្រែលមិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចក្នុងគោលបំណងជួយអន្តរាគមន៍បញ្ហារបស់ប្រជាពលរដ្ឋនោះទេ។

- **ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ (២រូប ចុះបាន៦លើក)៖** ខុមហ្វ្រែលទទួលបានព័ត៌មានតែការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រសរុប ៦លើក ក្នុងគោលបំណងចុះសួរសុខទុក្ខប្រជាជន (១លើក) ចូលរួមវេទិកា (១លើក) និងអមដំណើរថ្នាក់ដឹកនាំ (៤លើក)។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិមានដូចជា៖**

តំណាងរាស្ត្រ សៅ រ៉ានី មណ្ឌលព្រៃវែងបានចូលរួមវេទិកាសាធារណៈស្ដីពីសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍រៀបចំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ នៅភូមិប៉ាលហាល ឃុំរីករាយ ស្រុករវៀង ខេត្តព្រះវិហារ ហើយប្រជាជនដែលបានចូលរួមវេទិកា បានស្នើសូមឲ្យអ្នកតំណាងរាស្ត្រចុះជួយអន្តរាគមន៍លើករណីផ្ដល់ដីសម្បទានសេដ្ឋកិច្ចនៅតំបន់ព្រៃឡង់របស់រាជរដ្ឋាភិបាលទៅអោយក្រុមហ៊ុនស៊ីអស៊ីខេ (Chu Se Rubber Company Kampong Thom) និងក្រុមហ៊ុនភីអិនធីគ្រុប (PLT Group) និងការសម្បទានដីដែលជម្រកសត្វព្រៃបឹងពែរទៅឲ្យក្រុមហ៊ុនទ្រីភាពអ៊ីមផងអ៊ិចផត។ បន្ទាប់មកតំណាងរាស្ត្ររូបនេះបានចុះបានសរសេរជាលិខិតចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១ ស្នើសុំឲ្យឯកឧត្តម ច័ន្ទ សារុន ជារដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ដើម្បីពិនិត្យអំពីការផ្ដល់ដីសម្បទានសេចដ្ឋកិច្ចទៅ

ឲ្យក្រុមហ៊ុនទាំងនោះ ដោយស្វែងរកដំណោះស្រាយសមស្របកុំឲ្យប៉ះពាល់ដល់ជនជាតិដើមភាគតិចដែលរស់នៅជុំវិញតំបន់នោះ។

## សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ

### អតីតអ្នកតំណាងរាស្ត្រសមរង្ស៊ីនិងឱកាសចូលស្រុកវិញ

អតីតតំណាងរាស្ត្រ សម រង្ស៊ី ដែលបានភៀសខ្លួននៅក្រៅប្រទេសជិត២ឆ្នាំ ព្រោះគេចពីការផ្តន្ទាទោសរបស់តុលាការក្រុងភ្នំពេញនឹងត្រូវជាប់ពន្ធនាគារចំនួន១២ឆ្នាំនោះ អាចមានសង្ឃឹមថា អាចចូលស្រុកវិញបាន ប្រសិនបើងាកមកបន្ទន់ឥរិយាបថមកទន់ភ្លន់ចំពោះរាជរដ្ឋាភិបាល និងមានការជួយអន្តរាគមន៍ពីខាងសហគមន៍អន្តរជាតិដែលមានឥទ្ធិពលមិនឈប់ឈរមកលើរដ្ឋសភា និងរាជរដ្ឋាភិបាល។

ហើយការអវត្តមានរបស់អ្នកតំណាងរាស្ត្រសូម្បីតែ១រូប ក្នុងចំណោមអ្នកតំណាងរាស្ត្រ១២៣រូប ក៏មិនមែនជាសារល្អចំពោះស្ថាប័នរដ្ឋសភាក្នុងការត្រួតពិនិត្យស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល ការចុះជួប និងអន្តរាគមន៍ចំពោះម្ចាស់ឆ្នោតដែលជួបបញ្ហាប្រឈម ដូចជារឿងដីធ្លីជាដើម ហើយម្ចាស់ឆ្នោតក៏មិនសប្បាយចិត្តនៅពេលនៅពេលឃើញអ្នកនយោបាយមិនសហការគ្នាដែរ។

កន្លងមក ការសម្របសម្រួលនយោបាយធ្លាប់កើតមាន ដើម្បីអាចឲ្យអ្នកនយោបាយដែលមានទោស អាចនឹងរួចទោសវិញ តាមរយៈការស្នើរបស់រាជរដ្ឋាភិបាលទៅព្រះមហាក្សត្រដើម្បីប្រើព្រះរាជសិទ្ធិលើកលែងទោស តាមជំពូក២ មាត្រាទី២៧ នៃរដ្ឋធម្មនុញ្ញ "ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស" ប៉ុន្តែក្នុងនោះត្រូវមានការដោះដូរជាថ្នូរនឹងកត្តាផ្សេងៗជាមួយនឹងរាជរដ្ឋាភិបាល។

ថ្មីៗនេះ សញ្ញាវិជ្ជមានដែលអ្នកតំណាងរាស្ត្រ ជាម យៀប ជាប្រធានគណៈកម្មការទី២នៃរដ្ឋសភា និងជាអ្នកនាំពាក្យរបស់គណបក្សប្រជាជនកម្ពុជា បានផ្តល់ឲ្យអតីតតំណាងរាស្ត្រ សមរង្ស៊ី ក៏ដូចជាសមាជិកសភាមកពីគណបក្សសមរង្ស៊ី តាមប្រព័ន្ធផ្សព្វផ្សាយថា អតីតតំណាងរាស្ត្រ សមរង្ស៊ី អាចនឹងមានដំណោះស្រាយដើម្បីឲ្យអតីតតំណាងរាស្ត្ររូបនេះអាចនឹងចូលស្រុកវិញបានដោយមិនចាំបាច់ផ្តន្ទាទោស ប្រសិនបើអតីតតំណាងរាស្ត្រឈប់រិះគន់ វាយប្រហារ ហើយងាកមកសម្របឥរិយាបថជាមួយនឹងរាជរដ្ឋាភិបាល *"ក្រៅពីវិធីដែលគាត់ចេញពីពេលខាងមុខដែលគាត់សុំបាន។ ដូចមុន សម រង្ស៊ី ធ្លាប់បានគេដកអភ័យឯកសិទ្ធិធ្លាប់ជាប់គុកប៉ុន្មានដង។ ប៉ុន្តែរួចខ្លួនដោយសារតែព្រះករុណាអនុវត្តតាមជំពូក២ ព្រះមហាក្សត្រមានព្រះរាជសិទ្ធិលើកលែងទោស និងបន្ធូរបន្ថយទោស ឬក៏រដ្ឋសភាមានសិទ្ធិធ្វើច្បាប់លើកលែងទោស"*។

ជាការបើកផ្លូវ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងជាតំណាងរាស្ត្រកណ្តាលរបស់គណបក្សប្រជាជនកម្ពុជា បានថ្លែងបញ្ជាក់ពីជំហរជាអ្នកចាស់ទុំផ្នែកនយោបាយដោយចង់ឲ្យមានការដោះស្រាយអហិង្សារវាងអ្នកនយោបាយខ្មែរ និងបណ្តុះឲ្យមានសាមគ្គីភាពរវាងគ្នានិងគ្នា ដែលនេះជាការបញ្ជាក់ប្រាប់អតីតអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីថាដំណោះស្រាយតាមរយៈការចរចារបែបសន្តិភាព និងការបន្ទន់ឥរិយាបថជារបៀបអ្នកចាស់ទុំផ្នែកនយោបាយ គួរប្រើដាក់គ្នាទៅវិញទៅមក *«យើងគាំទ្រចំពោះអ្នកនយោបាយដែលមាន ឆន្ទៈនយោបាយបង្រួមបង្រួមគ្នា សាមគ្គីភាពគ្នា ឯកភាពគ្នា ក្នុងចំណុចដែលបម្រើផលប្រយោជន៍ជាតិរបស់យើង ពីព្រោះយើងមិនចង់បង្កឲ្យមានភាពតានតឹងអ្វីទាំងអស់»*។ លោកនាយករដ្ឋមន្ត្រី

ហ៊ុន សែន បានថ្លែងដូចនេះកាលពីថ្ងៃច័ន្ទ ទី១៣ ខែមិថុនា ឆ្នាំ២០១១ ក្នុងពិធីប្រគល់សញ្ញាប័ត្រដល់មន្ត្រីរាជការនៅសាលាភូមិន្ទរដ្ឋបាល។

នេះស្របពេលដែល សមាជិកសភាសហភាពអឺរ៉ុប លោកស្រី សេស៊ីល្យា វីកស្រ្តម បានស្នើរាជរដ្ឋាភិបាលកម្ពុជាក្នុងការសំរួលឲ្យអតីតអ្នកតំណាងរាស្ត្រ សម រង្ស៊ី អាចនឹងចូលប្រទេសវិញ ដើម្បីចូលរួមក្នុងយុទ្ធនាការបោះឆ្នោត២០១២ និង ២០១៣ខាងមុខនេះ ដើម្បីបង្ហាញពីភាពឈានឡើងនៃលទ្ធិប្រជាធិបតេយ្យរបស់កម្ពុជា។ មិនតែប៉ុណ្ណោះថែមទាំងបានសន្យាថានឹងនឹងនាំលោក សម រង្ស៊ី ចូលមកក្នុងប្រទេសកម្ពុជាវិញអំឡុងពេលឆាប់ៗមុនការបោះឆ្នោតសកលរបស់ប្រទេសនេះ *"វាប្រាកដច្បាស់ហើយថា ខ្ញុំនឹងធ្វើរបាយការណ៍ប្រាប់អង្គសភាស្តីពីគ្រោះថ្នាក់ចំពោះដំណើរការអនុវត្តលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា។ ហើយនៅពេលឃោសនាបោះឆ្នោតសកល វត្តមានរបស់លោក សម រង្ស៊ី នឹងនៅក្នុងប្រទេសកម្ពុជា"* ។ អ្វីដែលជាគន្លឹះនោះ គឺការដាក់សម្ពាធជាការយកពន្ធថ្លៃ និងព្យួរលើការនាំផលិតផលរបស់កម្ពុជាចូលទៅប្រទេសសហគមន៍អឺរ៉ុប ផ្អែកលើការរាយការណ៍ពីការរំលោភសិទ្ធិមនុស្ស បញ្ហាដីធ្លី នៅកម្ពុជា។

ដូចគ្នានេះដែរ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា លោក សុរិយាស៊ូប៊ែឌី (Surya Subedi)ក្នុងបេសកម្មរបស់គាត់ រយៈពេល៥ថ្ងៃនៅចុងខែឧសភា ឆ្នាំ២០១១ ខណៈដែលមានឱកាសសំដែងការគួរសមជាមួយនឹងប្រធានរដ្ឋសភាកម្ពុជា និងសមាជិករដ្ឋសភា បានស្នើសុំឲ្យមានការចាត់វិធានការធ្វើយ៉ាងណាផ្តល់និងការពារចំពោះប្រើប្រាស់សិទ្ធិបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រឲ្យបានគ្រប់រូប និងរួមទាំងនីតិវិធីនៃការដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ *"វិសាលភាពសម្រាប់សមាជិកសភា ក្នុងការចូលរួមជជែកដេញដោលត្រូវបានកម្រិត និងមានសមាជិកសភាមួយចំនួន ត្រូវបានដកអភ័យឯកសិទ្ធិ សូម្បីតែការបញ្ចេញមតិអំពីបញ្ហានានា ដែលជាផលប្រយោជន៍ជាតិក្តី"*។

ក្រៅពីនេះមាន ក៏មានសមាជិកសភាតំណាងរាស្ត្រឯករាជ្យមួយរូប ដែលមិននៅក្នុងគណបក្ស ឬក្រុមនយោបាយណាមួយ គឺលោក នីកូឡា ឌុបប៉ន់ អាងាន់ (Nicolas Dupont-Aignan) បានសរសេរលិខិតទៅរដ្ឋមន្ត្រីការបរទេសបារាំង និងកិច្ចការអឺរ៉ុប លោក Alain Juppe សុំឲ្យធ្វើអន្តរាគមន៍ អតីតតំណាងរាស្ត្រ សម រង្ស៊ី ដែលកំពុងនិរទេសខ្លួនក្នុងប្រទេសបារាំងបានចូលស្រុកវិញដោយសុវត្ថិភាព *"សុំឲ្យសហភាពអឺរ៉ុបកុំព្រងើយកន្តើយចំពោះការគាបសង្កត់ជនរងគ្រោះ ដែលជាតំណាងរាស្ត្របក្សជំទាស់ និងសុំឲ្យគេមានសិទ្ធិបំពេញការងារ ហើយមានសិទ្ធិនិយាយស្តីដូចដើម"* ។

កន្លងមក សភាអឺរ៉ុប ធ្លាប់បានធ្វើសេចក្តីសម្រេចចិត្តនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ ថ្កោលទោសការធ្វើទុក្ខបុកម្នេញទៅលើអតីតតំណាងរាស្ត្រ សម រង្ស៊ី និងក្រុមអ្នកជំទាស់ជាទូទៅ ហើយថាសាលក្រមរបស់តុលាការ គឺការបានរារាំងដល់អតីតតំណាងរាស្ត្រនេះ មិនបានចូលរួមក្នុងការឃោសនាបោះឆ្នោត ២០១៣ ហើយករណីអតីតតំណាងរាស្ត្រ សម រង្ស៊ី ក៏ធ្វើឲ្យប៉ះពាល់ដល់អ្នកតំណាងរាស្ត្រប្រឆាំងដ៏ទៃទៀតក្នុងការបញ្ចេញមតិ និងធ្វើសកម្មភាពដើម្បីការពារប្រយោជន៍ប្រជាជនផងដែរ ព្រោះតែសព្វថ្ងៃនេះ ការកាត់ទោសលើកការបញ្ចេញមតិរបស់តំណាងរាស្ត្រប្រឆាំងបានធ្វើឲ្យលំហនយោបាយកាន់តែតូចទៅ និងនាំទៅដល់ការធ្វើឲ្យខូចប្រយោធន៍ដល់ដំណើរលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាផងដែរ។

## ម្ចាស់ឆ្នោតសាទរ និងចាំមើលការសន្យារបស់អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាចដើម្បីដោះស្រាយបញ្ហាមគ្គុទេសក៍ជនជាតិកូរ៉េនៅស្រុកខ្មែរ

ម្ចាស់ឆ្នោតជាមគ្គុទេសក៍ភាសាកូរ៉េ (អ្នកនាំភ្ញៀវទេសចរណ៍ដើរកំសាន្តនិយាយភាសាកូរ៉េ) បានសាទរចំពោះការសន្យារបស់អ្នកតំណាងរាស្ត្រ ដែលថានឹងធ្វើអន្តរាគមន៍ទៅក្រសួងទេសចរណ៍ ចំពោះរឿងដែលអ្នកទេសចរជនជាតិកូរ៉េយកមគ្គុទេសក៍ជនជាតិកូរ៉េខ្លួនឯងដែលដណ្ដើមការងារមគ្គុទេសជនជាតិខ្មែរ។ ទោះបីយ៉ាងណាម្ចាស់ឆ្នោតទាំងនេះក៏កំពុងតែតាមដានការអនុវត្តការសន្យានេះដែរ។

អ្នកតំណាងរាស្ត្រ **ជាម យៀប** មកពីគណបក្សប្រជាជនកម្ពុជាមណ្ឌលព្រៃវែងថា គ្រោងនឹងកោះហៅរដ្ឋមន្ត្រីក្រសួងទេសចរណ៍មកបំភ្លឺនៅរដ្ឋសភា ពីបញ្ហាដោយសារតែជនជាតិកូរ៉េជាមគ្គុទេសក៍ភាសារកូរ៉េបាន ដណ្ដើមការងារមគ្គុទេសក៍ខ្មែរនិយាយភាសារកូរ៉េធ្វើឲ្យមគ្គុទេសក៍ខ្មែរអត់ការងារធ្វើនោះខាងក្រុមមគ្គុទេសក៍ខ្មែរចេះភាសារកូរ៉េ បានសាទរព័ត៌មានដែលតំណាងរាស្ត្របានមើលឃើញពីការលំបាករបស់ខ្លួន និងការជួយអន្តរាគមន៍ដែលខណៈក្រុមនេះកំពុងរងគ្រោះអត់ការងារធ្វើគេមិនឲ្យតំលៃបាក់ទឹកចិត្ត និងធ្លាក់ខ្លួនជាអ្នកកាន់ឆ័ត្រ និងស្បែកជើងឲ្យអ្នកទេសចរណ៍កូរ៉េដើរអមពីក្រោយមគ្គុទេសក៍ជនជាតិកូរ៉េទៅវិញ។ ហើយខាងមគ្គុទេសក៍កូរ៉េជនជាតិខ្មែរក៏រំពឹងចាំមើលពីកិច្ចអន្តរាគមន៍ និងចំណាត់ការបន្តបន្ទាប់ដើម្បីជួយចំរូលឲ្យគាត់មានការងារធ្វើហើយប្រកបដោយសេចក្តីថ្លៃថ្នូរវិញ។

អ្នកមគ្គុទេសក៍ជនជាតិខ្មែរភាសារផ្នែកកូរ៉េម្នាក់សូមមិនបញ្ចេញឈ្មោះ បានឆ្លើយទាំងសំលេងសប្បាយចិត្តលាយឡំនឹងការបារម្ភ ថាគាត់ពិតជាសប្បាយចិត្ត និងមានមោទនភាពជាខ្លាំងដែលតំណាងរាស្ត្របានមើលឃើញពីការលំបាករបស់ពួកគាត់ដែលកប់ជ្រៅក្នុងចិត្តអស់សង្ឃឹមយូរមកហើយ បែរជាត្រូវគាស់កកាយរំលេចដោយតំណាងរាស្ត្រដើម្បីឲ្យសាធារណជនទូទៅបានដឹងលឺផងដែរ *"ខ្ញុំសប្បាយចិត្តមែនទែននៅពេល ឯកឧត្តម ជាម យៀប មានប្រតិកម្មទៅរដ្ឋមន្ត្រីឲ្យជួយគិតគូរដល់ពួកខ្ញុំ។ ខ្ញុំសរសើរគាត់បានដឹងពីការលំបាករបស់ប្រជាជន មានមោទនភាពពេលឃើញអ្នកដឹកនាំ(អ្នកតំណាងរាស្ត្រ) ចេះជួយសំរាលទុក្ខលំបាករបស់ប្រជាជន។ យើងខំរៀនបានច្រើនតែគ្មានទីផ្សារ នេះជាបញ្ហា។ យើងមិនសប្បាយចិត្តដែលមានមគ្គុទេសក៍ជនជាតិកូរ៉េមកបកប្រែឲ្យភ្ញៀវទេសចរណ៍ជនជាតិកូរ៉េ ដែលវាធ្វើឲ្យចំណេះដឹងរបស់យើងថយចុះទៅពីមួយថ្ងៃទៅមួយថ្ងៃ។ បើផ្តល់ឱកាសឲ្យពួកយើងវិញយើងអាច នឹងព្យាយាមបកប្រែបន្តិចម្តងៗយើងនឹងអាចប្រាប់ភ្ញៀវទេសចរណ៍ពីអ្វីដែលប្រទេសយើងមានច្រើនជាងជនជាតិកូរ៉េ បើទោះជាភាសារយើងនៅមានកំរិត ពិសេសជនជាតិបរទេសគេចង់ឮផ្ទាល់ពីសំដីរបស់ម្ចាស់ទឹកដីផ្ទាល់"*។

មគ្គុទេសក៍ស្ត្រីជៀបវណ្ណារ៉ាត់ក៏បានពោលទាំងសំលេងសើចតិចៗបែបរំភើបថា" *សប្បាយចិត្តណាស់ និងសូមអរគុណគាត់ចេះគិតគូរដល់ប្រជាជនដឹងពីផលវិបាក កន្លងមកក្រសួងធ្លាប់ប្រាប់ថាខ្វះអ្នកចេះភាសាកូរ៉េត្រូវទ្រាំសិន*"។ កញ្ញាបានបន្ថែមទៀតថា កញ្ញាមានក្តីសង្ឃឹមថាតំណាងរាស្ត្រនឹងអាចជួយក្រុមមគ្គុទេសក៍ខ្មែរភាសាកូរ៉េបាន"*ខ្ញុំគិតថាគាត់អាចជួយបានខ្ញុំនឹងចាំមើលលទ្ធផលនេះ*"។

ទន្ទឹមនឹងនេះលោក សារឿម ជាមគ្គុទេសក៍មួយរូបក៏បានលើកឡើងដែរថា ជាការប្រសើរណាស់ចំពោះការលើកឡើងរបស់អ្នកតំណាងរាស្ត្រយើង ប៉ុន្តែជាក់ស្តែងវាពិបាកនឹងធ្វើចំនាត់ការព្រោះដោយសារខ្មែរយើងមិនមានក្រុមហ៊ុនទេសចរណ៍

ទទួលភ្ញៀវកូរ៉េធ្វើដំណើរកំសាន្តមកកម្ពុជា ទើបយើងពិបាកបញ្ច្រៀបមគ្គុទេសក៍ជនជាតិខ្មែរយើងក្នុងការនាំភ្ញៀវ" *គឺល្អថាជនជាតិខ្មែរមានការងារធ្វើ តែជារឿងពិបាកព្រោះថាជនជាតិកូរ៉េគេមានក្រុមហ៊ុនគេផ្ទាល់មានលុយច្រើនអាចទាក់ទាញទេសចរណ៍កូរ៉េបានច្រើនយើងមិនមានផ្លូវខ្មែរផ្ទាល់ធ្វើការរឿងហ្នឹង*"។

ជាមួយគ្នានេះដែរ អ្នកមគ្គុទេសក៍បានសំណូមពរជារួមថា សូមជួយពង្រឹងវិជ្ជាជីវៈបន្ថែមដល់មគ្គុទេសក៍ខ្មែរជាមគ្គុទេសក៍ភាសាកូរ៉េសូមបង្កើតសាលាផ្តល់ចំណេះដឹងភាសាកូរ៉េបានច្រើន និងមានបទសដ្ឋានត្រឹមត្រូវ ហើយគ្រូមានវិជ្ជាជីវៈច្បាស់លាស់ និងសូមរាជរដ្ឋាភិបាលជួយរៀបចំយ៉ាងណាឲ្យក្រុមមុគ្គទេសខ្មែរមានសិទ្ធិបានដើរផ្ទាល់មិនបាច់អមគេ។

ទោះបីយ៉ាងណា ខាងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឯកឧត្តម ថោង ខុន ធ្លាប់បានឆ្លើយតបតាមប្រព័ន្ធផ្សព្វផ្សាយថាកម្ពុជាមិនរើសអើងចំពោះជនជាតិណាមកធ្វើការរកស៊ីនៅកម្ពុជាទេ ហើយម្យ៉ាងកម្ពុជាពិតជាខ្វះមគ្គុទេសក៍ភាសាកូរ៉េមែន ដូចនេះទើបយើងសម្រេចចិត្តឲ្យមគ្គុទេសក៍ជនជាតិកូរ៉េធ្វើការសហការជាមួយមគ្គុទេសក៍ជនជាតិខ្មែរ គឺដើម្បីធ្វើយ៉ាងណារក្សាឲ្យភ្ញៀវទេសចរកូរ៉េមកទស្សនាកម្ពុជាបានច្រើនបន្តទៀត។

❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄

ទិន្នន័យការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រត្រូវបានប្រមូលមកពី៖ ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលនីមួយៗ សាខាគណបក្សជាប់ឆ្នោតនីមួយៗនៅតាមខេត្ត គេហទំព័រ (website) របស់គណបក្ស ប្រព័ន្ធផ្សព្វផ្សាយ និងរបាយការណ៍របស់អ្នកតំណាងរាស្ត្រ។

អ្នកតំណាងរាស្ត្រអាចផ្តល់ព័ត៌មានពីការចុះមូលដ្ឋានរបស់ខ្លួនតាមអាស័យដ្ឋានដូចខាងក្រោម៖


**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា**

ផ្ទះលេខ១៣៨ផ្លូវ១២២ទឹកល្អក់១ទួលគោកភ្នំពេញប្រអប់សំបុត្រលេខ១១៤៥
ទូរស័ព្ទ០២៣៨៨៤១៥០/០១២ ៩៤២ ០១៩ ទូរសារ០២៣៨៨៥៧៤៥
អ៊ីម៉េល៖comfrel@online.com.kh គេហទំព័រ៖www.comfrel.org